**គណបក្ស សមរង្ស៊ី អូស្ត្រាលី-ញ៉ូវហ្ស៊ីឡែន**

**SAM RAINSY PARTY AUSTRALIA-NEW ZEALAND**

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

# *សេចក្ដីអំពាវនាវបោះឆ្នោតឃុំ-សង្កាត់*

*បងប្អូនជនរួមជាតិ ជាទីគោរពទាំងឡាយ!*

***២០១២: ជាឆ្នាំដែលយើងត្រូវចាប់ផ្តើមបញ្ចប់អំពើជិះជាន់គាបសង្កត់នៅប្រទេសខ្មែរយើង***

*ថ្ងៃទី ៣ ខែមិថុនា ២០១២ ខ្មែរយើងចំនួន ៩.២ លាននាក់ នឹងមានសិទ្ធិចូលរួមបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ-សង្កាត់ ដែលជាការ បោះឆ្នោតមួយមានសារៈសំខាន់ជាទីបំផុតសំរាប់ ប្រជាជាតិខ្មែរយើង។*

*នេះគឺជាឱកាសដែលប្រជាពលរដ្ឋខ្មែរយើង អាចបញ្ចប់បាននូវរាល់អំពើជិះជាន់គាបសង្កត់គ្រប់បែបយ៉ាង ព្រោះនៅថ្នាក់ឃុំ-សង្កាត់នេះហើយដែល **គណបក្សប្រជាជន** ប្រើកម្លាំងឥទ្ធិពលនិងល្បិចគ្រប់បែបយ៉ាងរបស់គេ មកគាបសង្កត់គំរាមកំហែង ប្រជារាស្ត្រខ្មែរ ព្រោះនៅថ្នាក់ឃុំ-សង្កាត់នេះហើយ ដែលគេផ្ដល់បញ្ជីបោះឆ្នោតដល់ ជនអន្តោប្រវេស៍ ខុសច្បាប់។*

*ប្រជាពលរដ្ឋខ្មែរយល់ច្បាស់ណាស់ថា **គណបក្សប្រជាជន** នឹងបន្តការជិះជាន់គាបសង្កត់នេះ ដរាបណាគេនៅកាន់អំណាចតាមពិតទៅជាងសាមសិបឆ្នាំប្លាយនៃ ការជិះជាន់គឺល្មមហើយ!!*

*ការដឹងគុណក្នុងការរំដោះប្រជារាស្ត្រថ្ងៃ ៧ មករា មិនមែនមានន័យថាការផ្តល់សិទ្ធិឲ្យ **គណបក្សប្រជាជន** មករំលោភបំពានទឹកដីនិងប្រជារាស្ត្រខ្មែរជាងសាមសិបឆ្នាំប្លាយនោះទេ!!*

***សាមសិបឆ្នាំប្លាយនៃការជិះជាន់គាបសង្កត់គឺល្មមហើយ!!***

*មានតែការផ្លាស់ប្តូរថ្នាក់ដឹកនាំទេ ទើបអាចបញ្ចប់បាននូវការជិះជាន់រំលោភបំពាន ជាងសាមសិបឆ្នាំប្លាយនេះបាន។*
*មានតែ **គណបក្សសមរង្ស៊ី** ទើបអាចបញ្ចប់បាននូវការជិះជាន់រំលោភបំពាន ជាងសាមសិបឆ្នាំប្លាយនេះបាន។*
*មានតែ **គណបក្សសមរង្ស៊ី** ទើបអាចផ្តល់លទ្ធិប្រជាធិបតេយ្យនិងសេចក្ដីថ្លៃថ្នូរពិតប្រាកដមួយដល់ប្រជាពលរដ្ឋខ្មែរ។*

***គណបក្សសមរង្ស៊ី** ទទួលបានជាង ១.៣ លាននៃសល្លឹកឆ្នោតសរុបក្នុងឆ្នាំ ២០០៨ ហើយជាការគាំទ្រដែលមានការកើនឡើងជារាងរាល់ឆ្នាំ ដែលជាសក្ខីភាពបញ្ជាក់ថាប្រជាពលរដ្ឋខ្មែរ មានបំណងចង់បានការផ្លាស់ប្តូររបបនៅប្រទេសយើង។*

***គណបក្សសមរង្ស៊ី** នឹងចុះឈ្មោះបេក្ខជនចំនួន ១៦២១ នាក់ដើម្បីចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់ក្នុងចំណោម ឃុំ-សង្កាត់ទាំង ១៦៣៣។*

*ដើម្បីអាចចូលរួមបោះឆ្នោតនៃបេក្ខជនទាំង ១៦២១ ប្រកបដោយជោគជ័យបាន **គណបក្សសមរង្ស៊ី** ត្រូវការថវិកាយ៉ាងច្រើនដែលយើងមានការខ្វះខាតហើយពិបាកនឹងធ្វើទៅបានដោយគ្មានការគាំទ្រពីបងប្អូនជនរួមជាតិខ្មែរយើង។*

*យើងខ្ញុំសូមអំពាវនាវដល់សន្តានចិត្តបងប្អូនជនរួមជាតិគ្រប់រូប ក្នុងការជួយឧបត្ថម្ភជាថវិការដើម្បីចូលរួមបោះឆ្នោតនេះ។*

---

www.samrainsypartyanz.org
56 Grandview Rd, Wheelers Hill, Vic. 3150 AUSTRALIA
Email:srp.anz@gmail.com, vannamen@bigpond.net.au , Tel: 0417 062 938

# គណបក្ស សមរង្ស៊ី អូស្ត្រាលី-ញ៉ូវហ្ស៊ីឡង់

## SAM RAINSY PARTY AUSTRALIA-NEW ZEALAND

### សីលធម៌ សច្ចធម៌ យុត្តិធម៌

*បងប្អូនជនរួមជាតិអាចជួយសំរេចជោគជ័យដល់ **គណបក្សសមរង្ស៊ី** បានតាម ការជួយ ឧបត្ថម្ភ:*

- *៥ ដុល្លា អាចជួយផ្តល់ក្រដាសបោះពុម្ព ដើម្បីផ្សព្វផ្សាយពត៌មាននិងគោលនយោបាយគណបក្ស*
- *២៥ ដុល្លា អាចជួយផ្តល់អាហារ ៥ ពេល ដល់បេក្ខជនក្រុមប្រឹក្សាឃុំ- សង្កាត់ក្នុងការឃោសនាយុទ្ធការបោះឆ្នោតបាន ៥ ថ្ងៃ*
- *១០០ ដុល្លា អាចជួយផ្តល់ជាប្រេងសាំងដល់ បេក្ខជនក្រុមប្រឹក្សាឃុំ- សង្កាត់ ចំនួន ៤០នាក់ ក្នុងការឃោសនាបោះឆ្នោតបាន ៣០ ថ្ងៃ*
- *៣០០ ដុល្លា អាចជួយសំរេចជោគជ័យនៃ បេក្ខជនក្រុមប្រឹក្សាឃុំ- សង្កាត់ **គណបក្សសមរង្ស៊ី** បានមួយឃុំ*

*វិភាគទានរបស់បងប្អូន លោកនិងលោកស្រី អាចធ្វើជា* Cheque/Money Order *ឬបញ្ចូល នៅក្នុង* Account:

Commonwealth Bank of Australia
Account Name: Sam Rainsy Party ANZ
Account Number: 063171 10618237

*ពត៌មានបន្ថែម សូមទាក់ទងតាមខ្ញុំ ម៉ែន វណ្ណា*
*ទូរស័ព្ទ ០៤១៧ ០៦២ ៩៣៨*
Email: srp.anz@gmail.com or vannamen@bigpond.net.au

*សូមបងប្អូនទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងសេចក្តីស្រឡាញ់ស្មោះអំពីយើងខ្ញុំ។*

……………………..

*ម៉ែន វណ្ណា*
*ប្រធានក្រុមការងារនៃគណបក្សសមរង្ស៊ី អូស្ត្រាលី-ញ៉ូវហ្ស៊ីឡង់*
*ធ្វើនៅមែលប៊ួន ថ្ងៃទី ……. ខែ មិនា ឆ្នាំ ២០១២*


www.samrainsypartyanz.org
56 Grandview Rd, Wheelers Hill, Vic. 3150 AUSTRALIA
Email:srp.anz@gmail.com, vannamen@bigpond.net.au , Tel: 0417 062 938